# ខ្ញុំជាទំពាំង

១. ខ្ញុំជាទំពាំងក្នុងសង្គមបើក បាក់ឌុបកញ្ច្រើកប្រឡងយកជាប់

ខ្ញុំនៅតែឆ្ងល់កូនខ្មែររៀបរាប់ នេះជាទំលាប់ឬជាយ៉ាងណា? ។

២. ១២ឆ្នាំខ្ញុំប្រឹងរៀនរហូត តែជួនរបូត២ថ្ងៃសីហា

តាមពិតខ្ញុំមិន(មែន)ជាកូនទេវតា(fixed mindset) ខ្ញុំជាអ្នកស្នេហាសិក្សាខ្ចីឃ្នាត(growth mindset)។

៣. ប្រឡងពីរថ្ងៃដូចចាប់បង្ខំ ហើយកុំបន្ទំថាជាការស្រឡាញ់ជាតិ

មិនគួរអួតអាងអោយធំហួសមាឌ អង្គរកេរជាតិកើតដោយព្យាយាម ។

៤. អប់រំស្រុកខ្មែរត្រូវតែកែរទំរង់ ប្រឡងបាក់ឌុបគួរលប់ចេញភ្លាម

ដើរទាន់ពិភពលោកកូនខ្មែរទារទាម ទំពាំងមិនស្ងៀមចង់រីកធំជាក់ស្តែង ។

**សេង សុភ័ណ**

មើលកូនបណ្តើរហ្វេសប៊ុកបណ្តើរ

ម៉ោង១០ព្រឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

www.sophanseng.info